- នៅដំណាច់ឆ្នាំ សមតុល្យជាប្រាក់រៀលដែលបានពីការគណនាជាបន្តបន្ទាប់ ត្រូវតែតម្រូវឱ្យស្មើនឹងចំនួនទឹកប្រាក់ជារៀល ដែលបានមកពីសមតុល្យជាប្រាក់ដុល្លារអាមេរិក គុណនឹងអត្រាប្តូរប្រាក់នៅដំណាច់ខែធ្នូ។ លម្អៀងទឹកប្រាក់រវាងសមតុល្យជាប្រាក់រៀល ដែលបានពីការគណនាជាបន្តបន្ទាប់ និងសមតុល្យជាប្រាក់រៀលដែលបានពីការគណនាសមតុល្យជាប្រាក់ដុល្លារអាមេរិកនៅដំណាច់ឆ្នាំត្រូវចាត់ទុកជាចំណូលឬចំណាយថវិកា ដោយពុំមានរៀបចំអាណត្តិបើកប្រាក់និងសលាកបត្របង់ចំណូលឡើយ។

១៦-គណនី ចរន្ត នៅធនាគារស៊ីអាយអិមប៊ី “ លេខ ១១១៦ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ នៅធនាគារស៊ីអាយអិមប៊ី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើ ដែលកំពុងមាននៅធនាគារស៊ីអាយអិមប៊ី។

<u>ចំណាំ</u> : - គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារស៊ីអាយអិមប៊ី ជាប្រាក់រៀល (លេខ ១១១៦០១) និងគណនីចរន្តនៅធនាគារស៊ីអាយអិមប៊ី ជាប្រាក់ដុល្លារអាមេរិក (លេខ ១១១៦០២)។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារស៊ីអាយអិមប៊ី។
- ចំនួនទឹកប្រាក់ចំណូល ចំណាយនៅធនាគារស៊ីអាយអិមប៊ី ជាប្រាក់ដុល្លារអាមេរិក តែការកត់ត្រានៅរតនាគារជាប្រាក់រៀល ក្រោយពីការគិតតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។
- នៅដំណាច់ឆ្នាំ សមតុល្យជាប្រាក់រៀលដែលបានពីការគណនាជាបន្តបន្ទាប់ ត្រូវតែតម្រូវឱ្យស្មើនឹងចំនួនទឹកប្រាក់ជារៀល ដែលបានមកពីសមតុល្យជាប្រាក់ដុល្លារអាមេរិក គុណនឹងអត្រាប្តូរប្រាក់នៅដំណាច់ខែធ្នូ។ លម្អៀងទឹកប្រាក់រវាងសមតុល្យជាប្រាក់រៀល ដែលបានពីការគណនាជាបន្តបន្ទាប់ និងសមតុល្យជាប្រាក់រៀលដែលបានពីការគណនាសមតុល្យជាប្រាក់ដុល្លារអាមេរិកនៅដំណាច់ឆ្នាំត្រូវចាត់ទុកជាចំណូលឬចំណាយថវិកា ដោយពុំមានរៀបចំអាណត្តិបើកប្រាក់និងសលាកបត្របង់ចំណូលឡើយ។

១៧-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការចំណូល “ លេខ ១១២០ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារអេស៊ីលីដា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលបានបង្វែរពីធនាគារ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

<u>ចំណាំ</u> : - គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្តនៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

១៨-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការចំណាយ "លេខ ១១២១" :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារអេស៊ីលីដា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

<u>ចំណាំ</u> :
- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការចំណាយ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។
- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

១៩-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការចំណូល ចំណាយ ឃុំ សង្កាត់ "លេខ ១១២២" :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃប្រតិបត្តិការចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀលរបស់ឃុំ សង្កាត់ នៅធនាគារអេស៊ីលីដា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

<u>ចំណាំ</u> :
- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការចំណូល ចំណាយឃុំ សង្កាត់ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។
- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

២០-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស "លេខ ១១២៣" :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស នៅធនាគារអេស៊ីលីដា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

<u>ចំណាំ</u> :
- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេស៊ីលីដាសម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។
- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

២១-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ "លេខ ១១២៤" :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ នៅធនាគារអេស៊ីលីដា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

ចំណាំ :- គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្តនៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

២២-គណនី ចរន្ត នៅធនាគារអេស៊ីលីដា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា "លេខ ១១២៥ ":

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នៅធនាគារអេស៊ីលីដា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

ចំណាំ :- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេស៊ីលីដាសម្រាប់ប្រតិបត្តិការធានាការអនុវត្តកិច្ចសន្យា នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេស៊ីលីដា។

២៣-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៣០ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកាណាឌីយ៉ា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលបានបង្វែរពីធនាគារ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

ចំណាំ :- គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ាសម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

២៤-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណាយ " លេខ ១១៣១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកាណាឌីយ៉ា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ាសម្រាប់ប្រតិបត្តិការចំណាយ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

២៥-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណូល ចំណាយឃុំ សង្កាត់ " លេខ ១១៣២ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃប្រតិបត្តិការចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកាណាឌីយ៉ា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការចំណូល ចំណាយឃុំ សង្កាត់ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

២៦-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការផ្ទាត់បៀវត្ស " លេខ ១១៣៣ " :

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀលសម្រាប់ប្រតិបត្តិការបៀវត្សនៅធនាគារកាណាឌីយ៉ា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូល-ប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារកាណាឌីយ៉ាសម្រាប់ប្រតិបត្តិការប្រាក់បៀវត្ស នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

២៧-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការផ្ទាត់កក់ធានាការដេញថ្លៃ " លេខ ១១៣៤ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃនៅធនាគារកាណាឌីយ៉ា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូល-ប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្តនៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការដេញថ្លៃ នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

២៨-គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា “លេខ ១១៣៥ ”:

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ជាប្រាក់រៀល សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នៅធនាគារកាណាឌីយ៉ា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារជាសាច់ប្រាក់ឬដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្ត នៅធនាគារកាណាឌីយ៉ា សម្រាប់ប្រតិបត្តិការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិតត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកាណាឌីយ៉ា។

២៩-គណនី ចរន្ត នៅធនាគារវឌ្ឍនៈ សម្រាប់ប្រតិបត្តិការចំណូល “ លេខ ១១៤០ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារវឌ្ឍនៈ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារវឌ្ឍនៈ។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារវឌ្ឍនៈ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារវឌ្ឍនៈ។

៣០-គណនី ចរន្ត នៅធនាគារឯកទេសវីង សម្រាប់ប្រតិបត្តិការចំណូល “ លេខ ១១៥០ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារឯកទេសវីង។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារឯកទេសវីង។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារឯកទេសវីងសម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារឯកទេសវីង។

៣១-គណនី ចរន្ត នៅធនាគារអេប៊ីអេ សម្រាប់ប្រតិបត្តិការចំណូល “ លេខ ១១៦០ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារអេប៊ីអេ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេប៊ីអេ។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនីចរន្តនៅធនាគារអេប៊ីអេ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេប៊ីអេ។

៣២-គណនី ចរន្ត នៅធនាគារកម្ពុជាសាធារណៈ សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៧០ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារកម្ពុជាសាធារណៈ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារកម្ពុជាសាធារណៈ។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្តនៅធនាគារកម្ពុជាសាធារណៈ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារកម្ពុជាសាធារណៈ។

៣៣-គណនី ចរន្ត នៅធនាគារអេអិនហ្សេត រ៉ូយ៉ាល់ សម្រាប់ប្រតិបត្តិការចំណូល " លេខ ១១៨០ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលសាច់ប្រាក់ជាប្រាក់រៀលនៅធនាគារអេអិនហ្សេត រ៉ូយ៉ាល់។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាសាច់ប្រាក់ឬដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយពីធនាគារ ដោយបង្វែរ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើជាប្រាក់រៀល ដែលកំពុងមាននៅធនាគារអេអិនហ្សេតរ៉ូយ៉ាល់។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី គណនី ចរន្ត នៅធនាគារអេអិនហ្សេតរ៉ូយ៉ាល់ សម្រាប់ប្រតិបត្តិការចំណូល នៅតាមរាជធានី ខេត្តនីមួយៗ។ បញ្ជីរាយឈ្មោះនិងលេខអនុគណនីលម្អិត ត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ។

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីដែលមាននៅធនាគារអេអិនហ្សេត រ៉ូយ៉ាល់។

៣៤-គណនី ប្រាក់បញ្ញើរបស់ថវិកាឧបសម្ព័ន្ធ នៅរតនាគារ " លេខ ១២០១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់អង្គភាពដែលជាអ្នកអនុវត្តថវិកាឧបសម្ព័ន្ធ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយថវិកាដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០១ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកាឧបសម្ព័ន្ធ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់អង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ ដែលកំពុងមាននៅរតនាគារ

ចំណាំ : គណនីនេះ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិកាឧបសម្ព័ន្ធ (លេខ ៤៤០១) នៃប្លង់គណនេយ្យរដ្ឋ។

៣៥-គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ “ លេខ ១២០២ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០២ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការាជធានី ខេត្ត។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ
- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទទួលពីរតនាគារ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ
- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានពីរតនាគារដែលបានទូទាត់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់រាជធានី ខេត្ត ដែលកំពុងមាននៅរតនាគារ។

ចំណាំ : គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត (លេខ ៤៤០២) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។

៣៦-គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ “ លេខ ១២០៣ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០៣ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកាក្រុង ស្រុក ខណ្ឌ។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ
- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទទួលពីរតនាគារ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ
- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានពីរតនាគារដែលបានទូទាត់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ ដែលកំពុងមាននៅរតនាគារ។

ចំណាំ : គណនីនេះ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។

៣៧-គណនី ប្រាក់បញ្ញើរបស់ឃុំ សង្កាត់ នៅរតនាគារ “ លេខ ១២០៤ ” :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋបាលឃុំ សង្កាត់ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយ ដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០៤ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកាឃុំ សង្កាត់។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ
- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទទួលពីរតនាគារ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ
- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានពីរតនាគារដែលបានទូទាត់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ឃុំ សង្កាត់ ដែលកំពុងមាននៅរតនាគារ។

ចំណាំ : គណនីនេះ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ (លេខ ៤៤០៤) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។

៣៨-គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ " លេខ ១២០៥ " :

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០៥ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលកំពុងមាននៅរតនាគារ។

ចំណាំ :
- គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល (លេខ ៤៤០៥) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។
- គណនីនេះត្រូវចែកជាអនុគណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារ ជាប្រាក់រៀល (លេខ ១២០៥១) និងប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ ជាប្រាក់ដុល្លារអាមេរិក (លេខ ១២០៥២)។

៣៩-គណនី ប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ នៅរតនាគារ " លេខ ១២០៦ " :

គណនីនេះប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់សហគ្រាសសាធារណៈ ដែលផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយដែលជាប្រតិបត្តិការថវិកា និងប្រតិបត្តិការរតនៈវត្ថុ។ គណនីលេខ ១២០៦ ប្រើសម្រាប់កត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការបស់សហគ្រាសសាធារណៈ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ ដែលកំពុងមាននៅរតនាគារ។

ចំណាំ :
- គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់សហគ្រាសសាធារណៈ (លេខ ៤៤០៦) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរដ្ឋ។
- គណនីនេះត្រូវចែកជាអនុគណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច (លេខ ១២០៦១), ប្រាក់បញ្ញើរបស់ក្រុមហ៊ុនរដ្ឋ (លេខ ១២០៦២) និងប្រាក់បញ្ញើរបស់ក្រុមហ៊ុនចំរុះ (លេខ ១២០៦៣)។

៤០-គណនី ប្រាក់បញ្ញើមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ នៅរតនាគារ " លេខ ១២១១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រានៅក្នុងគណនេយ្យនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិនូវចំនួនទឹកប្រាក់ចំណូល ដែលបានពីថវិការដ្ឋ ដៃគូអភិវឌ្ឍន៍ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ក្រោមក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ និងពីប្រភពផ្សេងទៀត និងកត់ត្រាចំនួនទឹកប្រាក់ចំណាយ ដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការទូទាត់ចំណាយរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលជាប្រតិបត្តិការថវិកានិងប្រតិបត្តិការរតនៈវត្ថុ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំពុងមាននៅរតនាគារ។

ចំណាំ : គណនីនេះឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនី មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (លេខ ៤៤១១) ដែលកត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យថវិការដ្ឋ។

៤១-គណនី បេឡាសាច់ប្រាក់ " លេខ ១៣០១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូល ចំណាយសាច់ប្រាក់ពីបេឡា ជាប្រចាំថ្ងៃ

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនសាច់ប្រាក់ដែលបានបង់ចូលបេឡា

ឥណទាន : កត់ត្រាចំនួនសាច់ប្រាក់ដែលបានចំណាយពីបេឡា

សមតុល្យ : ឥណាយិក បង្ហាញចំនួនសាច់ប្រាក់ ដែលកំពុងមាននៅក្នុងបេឡា។

<u>ចំណាំ</u> : គណនីនេះត្រូវចែកជាអនុគណនី បេឡាសាច់ប្រាក់នៅរតនាគារកណ្តាល (លេខ ១៣០១១), នៅរតនាគាររាជធានី ខេត្ត (លេខ ១៣០១២), នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (លេខ ១៣០១៣), នៅអគ្គនាយកដ្ឋានពន្ធដារ (លេខ ១៣០១៤), នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល (លេខ ១៣០១៥) និងនៅអង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ (លេខ ១៣០១៦)។

៤២-គណនី រជ្ជទេយ្យករបុរេប្រទាន ថវិកាមិនមែនកម្មវិធី " លេខ ១៤០១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរជ្ជទេយ្យបុរេប្រទាន សម្រាប់ថវិកាមិនមែនកម្មវិធី ដែលបានទទួលពីរតនាគារ ឬពីធនាគារ តាមរយៈរជ្ជទេយ្យករបុរេប្រទាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនរជ្ជទេយ្យករបុរេប្រទានជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរជ្ជទេយ្យករបុរេប្រទានបានទូទាត់ តាមរយៈអាណត្តិបើកប្រាក់

- កត់ត្រាចំនួនទឹកប្រាក់ដែលរជ្ជទេយ្យករបុរេប្រទានបានបង់ជាសាច់ប្រាក់ចូលរតនាគារ ឬធនាគារ ដើម្បីជម្រះរជ្ជទេយ្យបុរេប្រទាន

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរជ្ជទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ ឬ អង្គភាពសាមី។

<u>ចំណាំ</u> : - ការគណនា ការបង្កើន ឬការបន្ថយកំរិតកំណត់រជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី គឺធ្វើនៅក្រៅកិច្ចបញ្ជិកាគណនេយ្យ។

- គណនីនេះ ត្រូវមានតំរូវហត្ថលេខារបស់រជ្ជទេយ្យករបុរេប្រទាន និងត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

- អគ្គនាយកដ្ឋានរតនាគារជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ អង្គភាពប្រហាក់ប្រហែល អាចបង្កើតបន្ថែមអនុគណនីនៃគណនី លេខ ១៤០១ សម្រាប់តាមដានជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ទៅតាមតម្រូវការចាំបាច់។

៤៣-គណនី រជ្ជទេយ្យករបុរេប្រទាន ថវិកាកម្មវិធី " លេខ ១៤០២ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាតាមកម្មវិធី ដែលបានទទួលពីរតនាគារ ឬ ពីធនាគារ តាមរយៈរជ្ជទេយ្យករបុរេប្រទាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនរជ្ជទេយ្យករបុរេប្រទានជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរជ្ជទេយ្យករបុរេប្រទានបានទូទាត់ តាមរយៈអាណត្តិបើកប្រាក់

- កត់ត្រាចំនួនទឹកប្រាក់ដែលរជ្ជទេយ្យករបុរេប្រទានបានបង់ជាសាច់ប្រាក់ចូលរតនាគារ ឬធនាគារ ដើម្បីជម្រះរជ្ជទេយ្យបុរេប្រទាន

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរជ្ជទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ ឬ អង្គភាពសាមី។

<u>ចំណាំ</u> : - ការគណនា ការបង្កើន ឬ ការបន្ថយកំរិតកំណត់រជ្ជទេយ្យបុរេប្រទាន ថវិកាកម្មវិធី គឺធ្វើនៅក្រៅកិច្ចបញ្ជិកាគណនេយ្យ។

- គណនីនេះ ត្រូវមានតំរូវហត្ថលេខារបស់រជ្ជទេយ្យករបុរេប្រទាន និងត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

- អគ្គនាយកដ្ឋានរតនាគារជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ អង្គភាពប្រហាក់ប្រហែល អាចបង្កើតបន្ថែមអនុគណនីនៃគណនី លេខ ១៤០២ សម្រាប់តាមដានជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ទៅតាមតម្រូវការចាំបាច់។

៤៤-គណនី អ្នកជាប់ពន្ធ " លេខ ១៥០១ " :

គណនីនេះ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បំណុលសារពើពន្ធដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន ឬ រូបវន្តបុគ្គល។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រាទៅក្នុងគណនីនេះ គឺយោងតាមរបាយការណ៍ ឬ សលាកបត្របង់ចំណូលថវិការបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានពន្ធដារ និងសាខា។

ការកត់ត្រា:

តទៅរាជកិច្ចលេខ ៣០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៩៩១ សហវ.ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតវិទ្យាល័យបុរេប្រទាន សម្រាប់ឆ្នាំ២០១៨ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែកប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ៤ ប្រការ៥ ប្រការ១៤ ក្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ២១៧ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០ "ការទិញ" ជំពូក៦១ "សេវាកម្ម" នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុង ប្រការ៥ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

ប្រការ ២.-

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

ប្រការ ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៤..

នាយកខុទ្ទកាល័យ អគ្គលេខាអធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរវត្ថុប្រធានគ្រប់អង្គភាពពាន់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ..................ខែ..........ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ,ថ្ងៃទី..............ខែ...........................ឆ្នាំ២០១៨

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ម៉ែន សំអន

<u>ចម្លងជូន៖</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និងអធិការកិច្ច

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានជវិភាគម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ២០១៨

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨	ឥណទានដែលជ្រើសរើស	ឥណទានរដ្ឋទេយ្យបុរេប្រទាន	ឥណទានទូទាត់ធម្មតា	ឥណទាន ១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ ជុំ	៦=៣/២
			សរុបរួម	12,344,000,000	8,907,900,000	6,890,900,000	2,017,100,000	1,722,725,000	77%
60			ការទិញ	4,144,000,000	1,140,900,000	370,500,000	770,500,000	92,625,000	32%
	6001		សម្ភារផ្គត់ផ្គង់ថែទាំ	1,932,000,000	182,000,000	54,600,000	127,400,000	13,650,000	30%
		60011	សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ	34,000,000	34,000,000	10,200,000	23,800,000	2,550,000	30%
		60012	សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ	74,000,000	74,000,000	22,200,000	51,800,000	5,550,000	30%
		60014	សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍	74,000,000	74,000,000	22,200,000	51,800,000	5,550,000	30%
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	1,750,000,000					
	6002		សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល	942,900,000	942,900,000	299,900,000	643,100,000	74,975,000	32%
		60021	សម្ភារៈការិយាល័យ	479,000,000	479,000,000	143,700,000	335,300,000	35,925,000	30%
		60022	សៀវភៅមើល និងឯកសារ	40,000,000	40,000,000	40,000,000		10,000,000	100%
		60023	ការបោះពុម្ព	423,900,000	423,900,000	116,200,000	307,800,000	29,050,000	27%
	6004		សំលៀកបំពាក់និងការតុបតែង	16,000,000	16,000,000	16,000,000		4,000,000	100%
		60014	ឯកសណ្ឋាន	16,000,000	16,000,000	16,000,000		4,000,000	100%
	6005		សម្ភារៈតូចតាច សង្ហារឹមនិងសម្ភារៈបរិក្ខារ	1,003,100,000					
		60051	សម្ភារៈនិងបរិក្ខារបច្ចេកទេសមិនមែនពត៌មានវិទ្យា	171,000,000					
		60052	សង្ហារឹម	230,000,000					
		60053	សម្ភារៈប្រើប្រាស់	52,000,000					
		60054	សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន	100,000,000					
		60055	សម្ភារៈនិងបរិក្ខារបច្ចេកទេសពត៌មានវិទ្យា	450,100,000					
	6006		ថាមពលនិងទឹក	250,000,000					
		60061	អគ្គិសនី	242,000,000					
		60062	ទឹក	8,000,000					
61			សេវាកម្ម	8,200,000,000	7,767,000,000	6,520,400,000	1,246,600,000	1,630,100,000	84
	6102		កាជួលមធ្យោបាយដឹកជញ្ជូន	50,000,000					
		61021	កាជួលមធ្យោបាយដឹកជញ្ជូន	50,000,000					
	6105		ការថែទាំនិងជួសជុល	1,190,000,000	1,190,000,000	413,000,000	777,000,000	103,250,000	35
		61052	ការថែទាំ ជួសជុលអគារ និងប្រាសាទ	960,000,000	960,000,000	288,000,000	672,000,000	72,000,000	30
		61056	ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន	150,100,000	150,100,000	45,100,000	105,000,000	11,275,000	30
		61057	ការថែទាំនិងជួសជុលសម្ភារៈ និង ឧបករណ៍បច្ចេកទេស	79,900,000	79,900,000	79,900,000		19,975,000	100
	6110		ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ	2,237,000,000	2,237,000,000	1,767,400,000	469,600,000	441,850,000	79
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	200,000,000	200,000,000	200,000,000		50,000,000	100
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	350,000,000	350,000,000	50,400,000	299,600,000	12,600,000	14
		61103	ប្រជុំសិក្ខាសាលា និងសន្និសីទ	1,480,000,000	1,480,000,000	1,330,000,000	150,000,000	332,500,000	90
		61104	ចំណាយរៀបចំពិធីបុណ្យ	70,000,000	70,000,000	70,000,000		17,500,000	100
		61105	ចំណាយសម្រាប់វត្តមនុស្សាវីរៈ នៅក្នុងនិងក្រៅប្រទេស	70,000,000	70,000,000	50,000,000	20,000,000	12,500,000	71
		61107	ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ	67,000,000	67,000,000	67,000,000		16,750,000	100
	6111		ចំណាយលើការជាវសារព័ត៌មាននិងឯកសារ	25,000,000	25,000,000	25,000,000		6,250,000	100
		61111	ចំណាយលើការជាវសារព័ត៌មាន	10,000,000	10,000,000	10,000,000		2,500,000	100
		61112	ចំណាយលើការជាវទស្សនាវដ្តី	5,000,000	5,000,000	5,000,000		1,250,000	100
		61118	ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ	10,000,000	10,000,000	10,000,000		2,500,000	100
	6112		ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស	4,300,000,000	4,300,000,000	4,300,000,000		1,075,000,000	100
		61121	សោហ៊ុយដឹកជញ្ជូន	80,000,000	80,000,000	80,000,000		20,000,000	100

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨	ឥណទានដែលជ្រើសរើស	ឥណទានផ្ទេរឲ្យបុរេប្រទាន	ឥណទានទូទាត់ធម្មតា	ឥណទាន ១ជុំ បង្វិលផ្ទេរឲ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ ជុំ	៦=៣/២
		61122	សោហ៊ុយបេសកម្ម	594,500,000	594,500,000	594,500,000		148,625,000	100%
		61123	សោហ៊ុយស្នាក់នៅ	3,625,500,000	3,625,500,000	3,625,500,000		906,375,000	100%
	6113		ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស	322,000,000					
		61131	សោហ៊ុយដឹកជញ្ជូន	200,000,000					
		61132	សោហ៊ុយបេសកម្ម	122,000,000					
	6114		សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍	76,000,000	15,000,000	15,000,000		3,750,000	100%
		61141	សោហ៊ុយប្រៃសណីយ៍	15,000,000	15,000,000	15,000,000		3,750,000	100%
		61142	សោហ៊ុយទូរគមនាគមន៍	61,000,000					

បានឃើញ និងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៨
ជ. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

មិញ្ញ បានសុវណ្ណអានិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា

និន-សាវ៉ាន់

បានឃើញ និងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨
អគ្គនាយករដ្ឋបាលកិច្ចការទូទៅ

ប៉ែន ច័ន្ទសុខរិន

រាជធានីភ្នំពេញថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨
រដ្ឋលេខាធិការប្រចាំការ

ចំរើន [illegible]

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១៨
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០១៨
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ម៉ែន សំអន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៨៣៦ ឧ.ស.ក.ប្រ.ក-១១

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដី ពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រ ផលិតនំគ្រប់ប្រភេទ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ម៉ាក្រូ (ខេមបូឌា) ឯ.ក ។

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាក្រូ (ខេមបូឌា) ឯ.ក (MAKRO (CAMBODIA) COMPANY LIMITED.) តំណាងដោយ លោក **NOPPACHAI MEETAM** បង្កើតរោងចក្រ ផលិតនំគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅ ផ្លូវលេខ១០០៣ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
នំគ្រប់ប្រភេទ	១០៧១

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ ៖ " រោងចក្រផលិតនំគ្រប់ប្រភេទ ម៉ាក្រូ (ខេមបូឌា) បេខឺរី **(Makro (Cambodia) Bakery)** "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
អនុរដ្ឋលេខាធិការ

មាន សុតា

បម្លងជូន៖
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលារាជធានីភ្នំពេញ
- -មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី